ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍បឹងត្រសែង

## រយៈពេល ០៣ឆ្នាំ
## ២០១៩~២០២១

កន្លែងនេសាទសហគមន៍ ៖ បឹងត្រសែង
ភូមិ ៖ រកា
៖ កំពីវ៉ង
សង្កាត់៖ ស្រយ៉ូវ
ក្រុង ៖ ស្ទឹងសែន
ខេត្ត ៖ កំពង់ធំ

# មាតិកា


១.ស្ថានភាពទូទៅ ........ ១

២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ........ ១

ក.ប្រជាពលរដ្ឋ ........ ២

ខ. មុខរបរ ........ ២

៣.កន្លែងនេសាទ និង ធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍ ........ ៣

ក. ទីតាំង ........ ៣

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៤

ឃ. ធនធានជលផល ........ ៤

១.ប្រភេទត្រី ........ ៤

២.ប្រភេទវារីសត្វ ........ ៤

៣.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ........ ៤

៤.ការធ្វើនេសាទ ........ ៤

ក.អ្នកនេសាទ ........ ៥

ខ.ឧបករណ៍នេសាទ ........ ៥

គ.ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

ក.ទស្សនៈវិស័យ ........ ៧

ខ.គោលបំណង ........ ៧

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៧

គ.២. ផែនការកែលម្អដែននេសាទ ........ ៨

គ.៣. ផែនការកំណត់និងរៀបចំកន្លែងអភិរក្ស ........ ៨

គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៩

គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

គ.៦.ផែនការថវិកាទ្រទ្រង់សម្រាប់ការអភិវឌ្ឍន៍សហគមន៍នេសាទ ........ ១០

គ.៧.ផែនការចុះល្បាតរបស់សហគមន៍នេសាទ ........ ១១

គ.៨.ផែនការពង្រឹងសម្ថតភាពគណៈកម្មការសហគមន៍នេសាទ ........ ១១

គ.៩.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១២

គ.១០. ផែនការជួសជុលស្នាក់ការសហគមន៍នេសាទ ........ ១២

គ.១១. ផែនការពង្រឹងបណ្តាញសហគមន៍នេសាទ និងចូលរួមប្រជុំផ្សេងៗ ........ [illegible]

គ.១២. ផែនការបង្កើតក្រុមសន្សំ ........ ១៣

គ.១៣. ផែនការបង្កើតមុខរបរទ្រទ្រង់ជីវភាពសមាជិកសហគមន៍នេសាទ ........ ១៣

ឃ. យុទ្ធសាស្ត្រ........................................................................................................................................ ១៤
៦.ឧបសម្ពន្ធ
ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០១៩-២០២១
ឧបសម្ពន្ធ ៖ តារាងកម្មវិធីការងារឆ្នាំ២០១៩-២០២១

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍ចឹងត្រាំសែង

**១.ស្ថានភាពទូទៅ**

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដែលជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ ដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផល នៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព សមភាព និងសមធម៌ តាមបែបសហគមន៍នេសាទ ក្នុងគោលបំណង ទទួលបានផលប្រយោជន៍ និងធ្វើអោយធនធានជលផលប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។

សហគមន៍នេសាទ**ចឹងត្រាំសែង** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតដំបូងនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ និងបានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧។

សហគមន៍នេសាទ**ចឹងត្រាំសែង**មានទីតាំងស្ថិតនៅក្នុងភូមិកោះនិងកំរ៉ែង សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដែលមានសមាជិកសរុបចំនួន ៣០៥នាក់ ស្រីមានចំនួន ១៣៤នាក់ និងមានគណៈកម្មការ ចំនួន ១១នាក់ ស្រីមានចំនួន ០៤នាក់ ក្នុងនោះចំនួនគ្រួសារសរុបមានចំនួន ៣០៥គ្រួសារ។

កន្លងមកសហគមន៍នេសាទ**ចឹងត្រាំសែង** បានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួនរួមមាន៖

- ផ្សព្វផ្សាយបង្កើនការយល់ដឹង អំពីទស្សនទានសហគមន៍នេសាទដល់ប្រជាពលរដ្ឋក្នុងភូមិ
- ចុះបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ
- បង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- បោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- កំណត់ព្រំប្រទល់ និងគូសផែនទីកន្លែងនេសាទសហគមន៍
- បោះបង្គោលព្រំប្រទល់កន្លែងនេសាទសហគមន៍
- ដាក់ស្លាកសញ្ញាសំគាល់កន្លែងអន្លង់អភិរក្ស
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផលកំពង់ធំ
- បានពិភាក្សារៀបចំធ្វើសេចក្តីព្រាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្នុងរយៈពេល ៣ឆ្នាំ
- បានរៀបចំវគ្គផ្សព្វផ្សាយស្តីពីសារៈប្រយោជន៍នៃការគ្រប់គ្រងធនធានជលផលដល់សមាជិកសហគមន៍
- ផ្សព្វផ្សាយច្បាប់អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងច្បាប់ជលផលស្តីពីជលផលនៅកម្ពុជា
- ចុះយាមល្បាតកន្លែងនេសាទសហគមន៍
- ប្រជុំប្រចាំខែក្នុងសហគមន៍នេសាទ
- បានចូលរួមប្រជុំប្រចាំខែជាមួយក្រុមព្រឹក្សាឃុំ
- បានចូលរួមធ្វើកម្មវិធីវិនិយោគឃុំ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក. ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមានចំនួន២៩០១នាក់ ប្រុស១៣៩៣នាក់ ស្រី៦៨៤នាក់
- ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%
- ចំនួនស្ត្រីមេម៉ាយសរុបក្នុងសហគមន៍នេសាទមានចំនួន ៨៨នាក់
- ចំនួនជនពិការសរុបក្នុងសហគមន៍នេសាទមានចំនួន ១៥ នាក់ ប្រុស០៨នាក់ ស្រី០៧នាក់
- ចំនួនចាស់ជរាសរុបក្នុងសហគមន៍នេសាទមានចំនួន ៣៧នាក់ ប្រុស១០នាក់ ស្រី២៧នាក់
- ចំនួនកុមារកំព្រាសរុបក្នុងសហគមន៍នេសាទមាន ០៩នាក់ ប្រុស០៦នាក់ ស្រី០៣នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃសរុបក្នុងសហគមន៍នេសាទមាន ២៤នាក់ ប្រុស១១នាក់ ស្រី១៣នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ៩៧% ក្រៅពីនេះមានអ្នកកាន់សាសនាកាតូលិក ៣% ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់
- អ្នកមិនចេះអក្សរមានចំនួន ២៣០នាក់ ប្រុស៦៥នាក់ ស្រី១៦៥នាក់
- កម្រិតថ្នាក់បឋមសិក្សាមានចំនួន ៤៥៩នាក់ ប្រុស១៦៣នាក់ ស្រី២៩៦នាក់
- កម្រិតថ្នាក់មធ្យមសិក្សាមានចំនួន ៧៣នាក់ ប្រុស២៨នាក់ ស្រី៤៥នាក់
- កម្រិតថ្នាក់ឧត្តមសិក្សាមានចំនួន ០២នាក់ ប្រុស០១នាក់ ស្រី០១នាក់។

### ខ. មុខរបរ

តាមរបាយការណ៍ និងឯកសារឃុំ បានបញ្ជាក់ថានៅក្នុងសហគមន៍**ចឹងត្រសែង** មានប្រពលរដ្ឋសរុបចំនួន ១៧១ គ្រួសារដែលពឹងផ្អែកលើការនេសាទ រីឯស្ត្រីគ្រាន់តែជាអ្នកប្រកបមុខរបរបន្ទាប់បន្សំដូចជាធ្វើស្រែចំការ ដាំបន្លែ និងលក់ដូរជាដើម។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបង ដែលជួយពង្រីកមុខរបរដល់ប្រជានេសាទ នៅក្នុងសហគមន៍ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើ ធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផលនិងអង្គការដៃគូអភិវឌ្ឍន៍ បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេស ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឲ្យមានការរីកចំរើន ពេលបច្ចុប្បន្នក្នុងសហគមន៍នេសាទ**ចឹងត្រសែង** ប្រជាពលរដ្ឋមានមុខរបរ សំខាន់ៗដូចជា៖

#### ខ.១. អ្នកដែលមានមុខរបរនេសាទ.

- ធ្វើនេសាទមានចំនួន ២០០គ្រួសារ .
- អ្នកកែច្នៃផលនេសាទ ដូចជាធ្វើផ្អក ប្រហុក និងត្រីឆ្អើរ មានចំនួន២០គ្រួសារគ្រួសារ (ជាលក្ខណៈគ្រួសារ)។

#### ខ.២. អ្នកដែលមានមុខរបរធ្វើអាជីវកម្ម ប៉ុន្តែមិនធ្វើនេសាទ

- ធ្វើស្រែមានចំនួន ៤៣៥ គ្រួសារ ទំហំ ៦៥២៥ហិកតា
- ធ្វើចំការមានចំនួន ៣២៨ គ្រួសារ ទំហំ ៦៥០ហិកតា
- ដាំបន្លែមានចំនួន ២០ គ្រួសារ
- ជាងផ្ទះមានចំនួន ០៧ គ្រួសារ
- លក់ដូរមានចំនួន ៣៤ គ្រួសារ
- ឡើងត្នោតមានចំនួន ០៨ គ្រួសារ
- បញ្ចូលអាគុយចំនួន ០៥ គ្រួសារ
- ម៉ាស៊ីនកិនស្រូវមានចំនួន ២២ គ្រួសារ និងម៉ាស៊ីនបោកស្រូវមានចំនួន ០៦ គ្រួសារ
- ម៉ាស៊ីនភ្លើងជីខ្នាតតូច ០៨ គ្រួសារ។

## ៣. កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងសហគមន៍នេសាទ**បឹងត្រសែង** មានទីតាំងស្ថិតនៅក្នុងភូមិរកា និងកំរែង សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ជាកន្លែងនេសាទបម្រុងទុកនៃដែននេសាទទឹកសាប។

កន្លែងសហគមន៍នេសាទ**បឹងត្រសែង** មានទំហំ៥៣៩ហិកតាហើយមានបឹងចំនួន០៣ អូរចំនួន០១ ព្រែកចំនួន០៧។ ត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រកាសទទួលស្គាល់។ កន្លែងនេសាទសហគមន៍**បឹងត្រសែង** មានព្រំប្រទល់ជាប់នឹង៖

- ខាងជើងទល់ នឹងភូមិរកា
- ខាងត្បូងទល់ នឹងស្ទឹងស្លាប់
- ខាងកើតទល់ នឹងព្រែកផ្សោត
- ខាងលិចទល់ នឹងវាលស្រែព្រែកអញ្ចាញ។

### ខ. ដែននេសាទ

កន្លែងសហគមន៍នេសាទ**បឹងត្រសែង** មានទំហំ៥៣៩ហិកតា មានបឹងចំនួន០៣ អូរចំនួន០១ និងព្រែកចំនួន០៧ ដែលបានគ្របដណ្តប់លើកន្លែងនេសាទសហគមន៍

- បឹងត្រសែង មានទំហំ ៦៤.០២ ហិកតា នេសាទពីខែវិច្ឆិកា ដល់ ខែឧសភា
- បឹងទឹកស្រាំ មានទំហំ ១០.៩៦ ហិកតា នេសាទពីខែវិច្ឆិកា ដល់ ខែឧសភា
- បឹងផុក មានទំហំ ១៣.២៨ ហិកតា នេសាទពីខែវិច្ឆិកា ដល់ ខែឧសភា
- អូរកំពង់ព្រួច មានទំហំ ៣៦.៨២ ហិកតា ជាកន្លែងអភិរក្ស
- ព្រែកកូនខ្លា ប្រវែង ២០០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា·
- ព្រែកបឹងផុក ប្រវែង ១៥០ម នេសាទពីខែមករា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រែកតាចង់ ប្រវែង ៥០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រែកបឹងទឹកស្រាំ ប្រវែង ១០០០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រែកតានប់សាប ប្រវែង ២០០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រែកជីមឿងសុខ ប្រវែង ១០០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រែកធំ ប្រវែង ៤០០ម នេសាទពីខែវិច្ឆិកា ដល់ ខែមីនា និង ឧសភា ដល់ ខែសីហា
- ព្រៃលិចទឹកមានទំហំសរុប ២១៤.០៦ហិកតា
- ព្រៃជុំវិញអូរកំពង់ព្រួច ៤៩.៦៥ហិកតា
- ព្រៃលិចទឹកមានទំហំសរុប ២១៤.០៦ហិកតា

### គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

កន្លែងនេសាទសហគមន៍**បឹងត្រសែង** បង្កើតកន្លែងអភិរក្សចំនួន០៤កន្លែង ដែលជាកន្លែងមានគុណភាពល្អ សម្រាប់អភិរក្សត្រីមេពូជ។

កន្លែងអភិរក្សត្រីមេពូជត្រូវបានធ្វើការគ្រប់គ្រងដោយសហគមន៍នេសាទមានដូចជា៖

| ល.រ | ឈ្មោះតំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស | ទំហំជាហិកតា | ប្រវែង | ជម្រៅ |
|---|---|---|---|---|
| ០១ | អន្លង់កំពង់រាំងក្នុងបឹងត្រសែង | ៤ | ២០០ម x ២០០ម | ៦ម |
| ០២ | អន្លង់បឹងទឹកស្រាំ | ១ | ១០០ម x ១០០ម | ៦ម |
| ០៣ | អន្លង់អូរកំពង់ធំក្នុងអូរកំពង់ព្រួច | ២.៥៨ | ៥៦០ម x ៥០ម | ៨ម |

**ឃ. ធនធានជលផល**

នៅប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ និងអាចរកប្រាក់ចំណូលពីការលក់ដូរផលនេសាទ ហើយនៅពេលដែលរដូវត្រីប្រហុក មកដល់ប្រជាជនតែងតែនាំគ្នាធ្វើប្រហុកផ្អកសម្រាប់បរិភោគ និងលក់បានមួយចំនួន។

**ឃ.១. ប្រភេទត្រី**

កន្លែងនេសាទសហគមន៍**បឹងត្រសែង** មានប្រភេទត្រីដូចជា៖ ត្រីរៀល ត្រីឆ្លាំង ត្រីកេះ ត្រីកញ្ចុះ ត្រីអាចម៍កុក ត្រីក្អែក ត្រីគ្រុំ ត្រីចិន ត្រីឆ្ពិន ត្រីកន្ត្រប់ ត្រីប្រម៉ា ត្រីគ្រសក់ ត្រីក្រាយ ត្រីក្រម៉ម ត្រីខ្ជឹង ត្រីខ្លា ត្រីរ៉ស់ ត្រីឆ្តោ ត្រីអណ្តែង ត្រីឆ្លូញ ត្រីចេកទុំ ត្រីកន្ធង ត្រីឆ្កោក ត្រីកញ្ចុះក្ដោង ត្រីក្រពត ត្រីចង្វា ត្រីដំរី ត្រីកំផ្លៀញ ត្រីផ្ទក់ ត្រីអណ្តាតឆ្កែ ត្រីឆ្ងៀត ត្រីក្លាំងហាយ ត្រីក្រាញ់ ត្រីព្រួល ត្រីស្លាបមាន់ ត្រីសង្កត់ប្រាក់ ត្រីក្រុះ ត្រីព្រួល ត្រីស្លាត ត្រីស្រកាក្តាម ត្រីកំភ្លៀវ ត្រីខ្មាន់ ត្រីគ្រុំ ត្រីដៀប ត្រីចង្វាមូល ត្រីក្លាំងហាយ ត្រីក្អែក ត្រីលិញ ។ល។

**ឃ.២. ប្រភេទវារីសត្វ**

កន្លែងនេសាទសហគមន៍**បឹងត្រសែង** មានប្រភេទវារីសត្វដូចជា៖ ក្តាម ខ្យង ខ្ចៅ គ្រំ លៀស អណ្តើក កន្ធាយ ពស់ កង្កែប ហ៊ីង គីង្គក់ អន្ទង់ ក្តាមទូក កន្ធេះឡង់ ក្រពើត្រី អន្សង់ កេ សត្វស្វាក្រុះ សំពោច ។ល។

**ឃ.៣. ប្រភេទបក្សី**

កន្លែងនេសាទសហគមន៍ **បឹងត្រសែង** មានប្រភេទបក្សីដូចជា៖ ក្អែកទឹក សត្វគ្រៀល សត្វទោម សត្វទុង សត្វប្រវឹកសត្វក្រសា សត្វកុកស សត្វមាន់ទឹក សត្វទាព្រៃ សត្វទាទឹក សត្វអូត សត្វទុង សត្វស្មោញ សត្វសេក សត្វលលក សត្វចាបសត្វត្រយង សត្វនោលខ្យង សត្វត្រដក់ សត្វក្រសា សត្វកំពឹងដូង ។ល។

**ឃ.៤. ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**

កន្លែងនេសាទសហគមន៍ **បឹងត្រសែង** មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ដើមរាំងទឹក ដើម តាអួរ ដើមអញ្ចាញ ដើមថ្វាន់ ដើមកន្សែង ដើមបន្លាយួន ដើមស្នាចទឹក ដើមកណ្តាប់ចង្កេរ ដើមរំដេញ ដើមបន្លាស្អិត។ល។

**៤. ការធ្វើនេសាទ**

ការធ្វើនេសាទជាមុខរបរចាំបាច់ សម្រាប់ការចិញ្ចឹមជីវិតរបស់សមាជិកសហគន៍នេសាទ**បឹងត្រសែង** ផលិតផលត្រីត្រូវបានធ្វើអាជីវកម្មក្នុងតំបន់ផ្ទាល់ ដើម្បីរកចំណូលពេលបច្ចុប្បន្នប្រជាពលរដ្ឋទាំងអស់ ក្នុងសហគមន៍**បឹងត្រសែង** បានផ្តោតលើការនេសាទដោយបានប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ក្នុងការទាញយកផលនេសាទ ផែនការនេសាទរបស់សមាជិកសហគមន៍ និងអ្នកខាងក្រៅត្រូវបានអនុវត្តស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីគ្រប់គ្រងដែនសាទ ផែនការគ្រប់គ្រងរបស់សហគមន៍នេសាទដែលបានរៀបចំសម្រាប់ឆ្នាំ២០១៩ដល់ឆ្នាំ២០២១។

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ៣១២នាក់ ស្រីមានចំនួន ១៧៨នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នៅក្នុងសហគមន៍មានចំនួន ៧២០នាក់ ស្រីមានចំនួន ៣៤៨នាក់
- តាមការប៉ាន់ស្មានអ្នកនេសាទ ដែលមកពីខាងក្រៅហើយមិនមែនជាសមាជិកសហគមន៍មានប្រហែល០៨នាក់ ស្រី០៣នាក់ ក្នុង១ឆ្នាំនៅក្នុងកន្លែងនេសាទសហគមន៍។

**ខ. ឧបករណ៍នេសាទ**

នៅរដូវបើកនេសាទប្រជាជននៅក្នុងសហគមន៍នេសាទ**ចឹងគ្រាំសែង** និងអ្នកខាងក្រៅ តែងតែធ្វើនេសាទ ដោយប្រើប្រាស់ប្រភេទឧបករណ៍នេសាទលក្ខណៈគ្រួសារ ដូចជា លប មង សន្ទូច លបព្រៀង ទ្បើ លាន់ និងជុច។ល។ សមាជិកនិងគណៈកម្មការសហគមន៍នេសាទ**ចឹងគ្រាំសែង** បានធ្វើការប៉ាន់ប្រមាណពីតម្រូវ ការប្រភេទឧបករណ៍ ដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រង ជាពិសេសសមាជិក និងគណៈកម្មការសហគមន៍នេសាទ បានស្នើសមត្ថកិច្ចជំនាញជលផលធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ នេសាទនិងអ្នកនេសាទមកពីខាងក្រៅ លើប្រភេទឧបករណ៍នេសាទ ដែល ហាមឃាត់ដូចជា ឧបករណ៍ឆក់ត្រី អ៊ុយស្នែមុង គ្រាប់បែក។ល។

**ឧបករណ៍នេសាទ ទូក និងកាណូត របស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍ដូចជា៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៤០ម) | ៤០ម x ៧១ដៃ | ៣-៩ហ៊ុន x ២.៥ម x ២៨៤០ម | ខែមករា ដល់ ខែធ្នូ |
| ០២ | សំណាញ់ | វង់ | ៣៥នាក់ x ១ | ៣-៤ហ៊ុន x ១២ហាត់ | ខែមករា ដល់ ខែមីនា |
| ០៣ | សន្ទូច | ផ្លែ | ១សាង=១០០ | ៩០០ផ្លែ លេខ១២-១៥ | ខែកញ្ញា ដល់ ខែធ្នូ |
| ០៤ | លប | គ្រឿង | ១នាក់ x ២ | ០,៦ម x ១,៦ម x ៣សម | ខែមិថុនា ដល់ ខែកញ្ញា |
| ០៥ | អួនហ៊ុំ | វង់ | ៩នាក់ x ៦០ម | ២-៤ ស.ម x ៦ម | ខែមករា ដល់ ខែមីនា |
| ០៦ | អួនប្រយ៉ុង | វង់ | ៩នាក់ x ៦០ម | ២-៤ ស.ម x ៧ម | ខែមករា ដល់ ខែមីនា |
| ០៧ | លបត្រីដំរី | គ្រឿង | ១៥នាក់ x ២ | ០,៦០ម x ១,៥០ម | ខែកុម្ភៈ ដល់ ខែមេសា |
| ០៨ | អញ្ចង | វង់ | ១នាក់ x ២ | ១,៥ ស.ម x ២ម | ខែមករា ដល់ ខែមីនា |
| ០៩ | សៃយ៉ឺន | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,៥០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១០ | បង្កៃ | ផ្លែ | ៣នាក់ x ១០០ | លេខ៧-១០ | ខែកញ្ញា ដល់ ខែវិច្ឆិកា |
| ១១ | ឈ្នាង | គ្រឿង | ២នាក់ x ១ | ០,៦០ម x ១,២០ម | ខែធ្នូ ដល់ ខែកក្កដា |
| ១២ | លាន់ | គ្រឿង | ១០នាក់ x ៦០ | ០,៧០ម x ១,៥០ម | ខែមិថុនា ដល់ ខែមីនា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ១០០ | ៣០០ - ៥០០ | ៦ ដ[illegible] |
| កាណូតម៉ាស៊ីនតូច | ១៥០ | ៥០០ - ១តោន | ១[illegible] |
| ទូកអុំ | ១០០ | ១០០ | |

**ឧបករណ៍នេសាទ ទូក និងកាណូត របស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ ដែលប្រើប្រាស់៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៤០ម) | ៤០ម x ២០ដៃ | ២-៥ ស.ម x ៣ម | មួយឆ្នាំពេញ |
| ០២ | អួនប្រយ៉ុង | វង់(៣០ម) | ១៥នាក់ x ៣០ម | ២-៤ ស.ម x ៧ម x ១៥០ម | ខែមករា ដល់ ខែមីនា |
| ០៣ | សន្ទូច | ផ្លែ(២០០) | ២០នាក់ x ២០០ | លេខ១២-១៥ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៤ | លបត្រីដំរី | គ្រឿង | ៨នាក់ x ១៥ | ០,៦០ម x ១,៥០ម ចន្លោះគ្រៀម ២ស.ម | ខែកុម្ភៈ ដល់ ខែមេសា |
| ០៥ | អួនហ៊ុំ | វង់ | ៦នាក់ x ៦០ម | ២-៤ ស.ម x ៦ម x ៣៦ម | ខែមករា ដល់ ខែមីនា |
| ០៦ | ចាន់ | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៧ | ទ្រូ | គ្រឿង | ៦៥នាក់ x ២ | ០,៦០ម x ១,២០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៨ | តុំឬកន្សុំ | គ្រឿង | ២៥នាក់ x ២ | ២,៥-៤ហ៊ុន x ៦ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ០៩ | សៃយឺន | គ្រឿង | ១នាក់ x ១ | ០,៦០ម x ១,៥០ម | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១០ | បង្កៃ | ផ្លែ | ៣នាក់ x ១០០ | លេខ៧-១០ | ខែមិថុនា ដល់ ខែវិច្ឆិកា |
| ១១ | ឈ្នាង | គ្រឿង | ២នាក់ x ១ | ០,៦០ម x១,២០ម | ខែធ្នូ ដល់ ខែមេសា |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ១៥ | ៣០០ - ៥០០ | ១៨ ដល់ ៣៥ |
| កាណូតម៉ាស៊ីនតូច | ៤៨ | ៥០០ - ១តោន | ៦ ដល់ ១៨ |
| ទូកអុំ | ៥០ | ១០០ | |

**ឧបករណ៍នេសាទ ទូក និងកាណូត របស់អ្នកមិនមែនជាសមាជិកសហគមន៍នេសាទដែលមកពីខាងក្រៅ៖**

| ល.រ | ឧបករណ៍ | ឯកតា | ចំនួន | ប្រវែង/ទំហំ | រដូវនេសាទ |
|---|---|---|---|---|---|
| ០១ | មង | ដៃ(៥០ម) | ៥០ម x១០ដៃ | ៤-៩ហ៊ុន x ២.៥ម | មួយឆ្នាំពេញ |
| ០២ | បង្កៃ | ផ្លែ(១០០) | ១០នាក់ x ៥០ | លេខ៧-៩ | មួយឆ្នាំពេញ |
| ០៣ | សន្ទូចនេង | ផ្លែ(១០០) | ១០សាង=១០០ | លេខ១៤-១៦ | មួយឆ្នាំពេញ |
| ០៤ | សំណាញ់ | វង់ | ១០នាក់ x ១ | ៣-៤ហ៊ុន x ១២ហាត់ | មួយឆ្នាំពេញ |

| ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ (គក) | កំលាំងសេះ |
|---|---|---|---|
| កាណូតម៉ាស៊ីនធំ | ២៥ | ៣០០ - ៥០០ | ១៨ ដល់ ៣៥ |
| កាណូតម៉ាស៊ីនតូច | ៣២ | ៥០០ - ១តោន | ៦ ដល់ ១៨ |
| ទូកអុំ | ០០ | ០០ | |

## គ. ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់ប្រភេទ | ២,៥០០ | ១,៥០០ | ៤,០០០ |
| ក្ដាម ខ្យង ខ្ចៅ និងលៀស | ២៥០ | ៣៥០ | ៦០០ |
| អន្ទង់ | ៣៥០ | ៤៥០ | [illegible] |
| **សរុប** | **៣,១០០** | **២,៣០០** | **៥,៤០០** |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ**ចឹងគ្រសែង** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងនិរន្តរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប ជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ ទំនាបលិចទឹកក្នុងរដូវទឹកដំឡើងព្រៃលិចទឹក និងកន្លែងអន្លង់អភិរក្ស។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងជានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ដើម្បីធ្វើឲ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។
- ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១. ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយបាន គិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុក ដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឲ្យការធ្វើនេសាទ លើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទ**ចឹងគ្រសែង** ត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| ឈ្មោះកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើកន្លែងនេសាទសហគមន៍ | | | |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | ផ្សេងៗ |
| **ចឹងគ្រសែង** | ខែមករាដល់ខែធ្នូ | មង | ក្រឡា= ២,៥ - ៦ស.ម<br>សម្រុង= ១ម - ១,៤០ម | ២០នាក់ ក្នុង១ថ្ងៃ | ១នាក់=១០០ម |
| | ខែមករាដល់ខែធ្នូ | សន្ទូច | ផ្លែលេខ ១២ ១៣ | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=២៥០ផ្លែ |
| | ខែវិច្ឆិកាដល់ខែមករា | បង្កៃ | ផ្លែលេខ ១៤ | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១០០ផ្លែ |
| | ខែមករាដល់ខែធ្នូ | លបកញ្ជះ | ០,៥០ម x ១,៥០ម | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១៦គ្រឿង |
| | ខែមករាដល់ខែធ្នូ | លបត្រីដំរី | ០,៦០ម x ១,៨០ម | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=២០០គ្រឿង |
| | ខែមករាដល់ខែមីនា | លបលួង | ០,៣០ម x ០,៦០ម | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០គ្រឿង |
| | ខែមករាដល់ខែឧសភា | បបក់ | | ៤នាក់ ក្នុង១ថ្ងៃ | ១នាក់=១បបក់ |
| | ខែមីនាដល់ខែមេសា | ឈ្នាង អង្រុត | | ១នាក់ ក្នុង១ថ្ងៃ | ១នាក់=២០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | លាន់ | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | ប៉ោង | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| **ទឹកស្រាំ** | ខែមករាដល់ខែធ្នូ | មង | ក្រឡា= ២,៥ - ៦ស.ម<br>សម្រុង= ១ម -១,៤០ម | ៣នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០ម |
| | | សន្ទូច | ផ្លែលេខ ១២ ១៣ | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=២៥០ផ្លែ |
| | ខែវិច្ឆិកាដល់ខែមករា | បង្កៃ | ផ្លែលេខ ១៤ | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១០០ផ្លែ |
| | ខែមករាដល់ខែធ្នូ | លបកញ្ជះ | ០,៥០ម x ១,៥០ម | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១៦គ្រឿង |
| | ខែមករាដល់ខែធ្នូ | លបត្រីដំរី | ០,៦០ម x ១,៨០ម | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=២០០គ្រឿង |

| | | | | | |
|---|---|---|---|---|---|
| | ខែមករាដល់ខែមីនា | លបល្អង | ០,៣០ម x ០,៦០ម | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០គ្រឿង |
| | ខែមករាដល់ខែឧសភា | បបក់ | | ៤នាក់ ក្នុង១ថ្ងៃ | ១នាក់=១បបក់ |
| | ខែមីនាដល់ខែមេសា | ឈ្នាង អង្រុត | | ១នាក់ ក្នុង១ថ្ងៃ | ១នាក់=២០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | លាន់ | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | ប៉ោង | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| ចឹងផុក | ខែមករាដល់ខែធ្នូ | មង | ក្រឡា= ២,៥ - ៦ស.ម<br>សម្រុង= ១ម -១,៤០ម | ៣នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០ម |
| | ខែមករាដល់ខែធ្នូ | សន្ទូច | ផ្លែលេខ ១២ ១៣ | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=២៥០ផ្លែ |
| | ខែវិច្ឆិកាដល់ខែមករា | បង្កៃ | ផ្លែលេខ ១៤ | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១០០ផ្លែ |
| | ខែមករាដល់ខែធ្នូ | លបកញ្ជះ | ០,៥០ម x ១,៥០ម | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១៦គ្រឿង |
| | ខែមករាដល់ខែធ្នូ | លបត្រីជីវី | ០,៦០ម x ១,៨០ម | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=២០០គ្រឿង |
| | ខែមករាដល់ខែមីនា | លបល្អង | ០,៣០ម x ០,៦០ម | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០គ្រឿង |
| | ខែមករាដល់ខែឧសភា | បបក់ | | ៤នាក់ ក្នុង១ថ្ងៃ | ១នាក់=១បបក់ |
| | ខែមីនាដល់ខែមេសា | ឈ្នាង អង្រុត | | ១នាក់ ក្នុង១ថ្ងៃ | ១នាក់=២០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | លាន់ | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | ប៉ោង | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| អូរកំពង់ព្រួច | ខែមករាដល់ខែធ្នូ | មង | ក្រឡា= ២,៥ - ៦ស.ម<br>សម្រុង= ១ម -១,៤០ម | ៣នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០ម |
| | ខែមករាដល់ខែធ្នូ | សន្ទូច | ផ្លែលេខ ១២ ១៣ | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=២៥០ផ្លែ |
| | ខែវិច្ឆិកាដល់ខែមករា | បង្កៃ | ផ្លែលេខ ១៤ | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១០០ផ្លែ |
| | ខែមករាដល់ខែធ្នូ | លបកញ្ជះ | ០,៥០ម x ១,៥០ម | ៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១៦គ្រឿង |
| | ខែមករាដល់ខែធ្នូ | លបត្រីជីវី | ០,៦០ម x ១,៨០ម | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=២០០គ្រឿង |
| | ខែមករាដល់ខែមីនា | លបល្អង | ០,៣០ម x ០,៦០ម | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=៣០គ្រឿង |
| | ខែមករាដល់ខែឧសភា | បបក់ | | ៤នាក់ ក្នុង១ថ្ងៃ | ១នាក់=១បបក់ |
| | ខែមីនាដល់ខែមេសា | ឈ្នាង អង្រុត | | ១នាក់ ក្នុង១ថ្ងៃ | ១នាក់=២០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | លាន់ | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| | ខែវិច្ឆិកាដល់ខែមេសា | ប៉ោង | | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=៥០គ្រឿង |
| | ខែតុលាដល់ខែធ្នូ | សំណាញ់ | ក្រឡា=២,៥-៥ស.មx៥ម | ១០នាក់ ក្នុង១ថ្ងៃ | ១នាក់=១វង់ |
| | ខែមករាដល់ខែមេសា | អួនព្រយ៉ុង | ក្រឡា=៣,៥-៥ស.មx៤ម | ១៥នាក់ ក្នុង១ថ្ងៃ | ១នាក់=១វង់ |

## គ.២. ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារមានការគាំទ្របច្ចេកទេស និងថវិកា និងប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះវាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ សមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន ក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាល បានពិនិត្យឃើញថាដែននេសាទនៅក្នុងសហគមន៍នេសាទ **ចឹងត្រសេក** មានសភាពប្រែប្រួលខ្លះ ដែលបណ្តាល មកពីកត្តាមនុស្ស និងធម្មជាតិ ដូចជាព្រៃកដែលធ្វើចរាចរទទួលនូវ ការរើពក ដែលបណ្តាលមកពីការដាក់ក្នុងអូរ និងការហូរច្រោះដោយសារការកាប់ទន្រ្ទាញព្រៃលិចទឹកនៅតាមមាត់បឹង ។

ផែនការកែលំអដែននេសាទ ក្នុងគោលបំណង

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ។
- ធ្វើឱ្យសំបូរព្រៃលិចទឹកឲ្យនៅក្នុងដែននេសាទសហគមន៍។

ផែនការកែលំអដែននេសាទសហគមន៍**បឹងត្រសែង** នឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះដែននេសាទ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| **បឹងទឹកស្រាំ** | ១ហិកតា | សាងសង់ទំនប់បង្ហៀរ លើកទំនប់ | ខែធ្នូ ២០១៩ | ខែធ្នូ ២០១៩ |
| | | បណ្ដោយ១០ម ខ្នង៥ម បាត៨មកំពស់១,៥ | ខែធ្នូ ២០២០ | ខែធ្នូ ២០២០ |

## គ.៣. ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

កន្លែងសហគមន៍នេសាទ**បឹងត្រសែង** បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០២កន្លែង គឺអន្លង់ថ្មពង និងអន្លង់អូរស្ដើង ដែលជាកន្លែងមានសក្ដានុពលសម្រាប់អភិរក្សត្រីមេពូជ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ**បឹងត្រសែង** ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយ កន្លែងអភិរក្សត្រីមេពូជទាំង០២កន្លែងនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹក ដែលជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្ដល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ចូលរួមការពារធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

កន្លែងអភិរក្សត្រីមេពូជ ជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គោលស៊ីម៉ង់ ផ្សព្វផ្សាយ ក្តារខៀនព័ត៌មានបិទផ្សាយបទបញ្ញត្តិផ្សេងៗ សាងសង់រោងយាម សម្រាប់ក្រុមល្បាតបំពេញការងារ និង សម្ភារៈ ផ្សេងទៀត។

**ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖**

| ទីតាំង | ទំហំ ហត | ប្រភេទនៃការអភិរក្ស | សកម្មភាព | ខែ ឆ្នាំ ចាប់ផ្ដើម | ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **អន្លង់កំពង់រាំង** | ៤ | ត្រីមេពូជ | - ធ្វើស្លាកសញ្ញាអន្លង់អភិរក្សត្រីមេពូជ និងធ្វើបង្គោល<br>- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ<br>- កំណត់ និងបោះបង្គោលព្រំប្រទល់<br>- បោះស្លាកសញ្ញាអភិរក្ស<br>- ទំលាក់គល់ឈើ និងលូស៊ីម៉ង់<br>- ចុះល្បាតការពារកន្លែងអភិរក្ស<br>- សង់រោងយាម | ២០១៩ | ២០២១ |
| **អន្លង់បឹងទឹកស្រាំ** | ១ | | | | |
| **អន្លង់អូរកំពង់ធំ** | ២.៥៨ | | | | |

## គ.៤. ផែនការគ្រប់គ្រងព្រៃលិចទឹក

នាទីព្រៃលិចទឹក បានគ្របដណ្តប់លើដែននេសាទសហគមន៍**បឹងត្រសែង** ដែលបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រី សត្វល្មូន និងវារីសត្វផ្សេងទៀត សម្រាប់ជាជម្រក និងរស់នៅបង្កកំណើតផង ព្រមទាំងជាប្រភពចំណីផងដែរ។

ផែនការគ្រប់គ្រងព្រៃលិចទឹកក្នុងគោលបំណង

- ថែរក្សា ការពារព្រៃលិចទឹកឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឲ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅ។

**ខាងក្រោមនេះជាផែនការគ្រប់គ្រងនាទីព្រៃលិចទឹកក្នុងសហគមន៍នេសាទពាម បឹងត្រសែង មានដូចជា៖**

| ឈ្មោះ ទីតាំង | ទំហំ ហិកតា | កូនឈើដែលត្រូវការពារ | សកម្មភាព | ខែ ឆ្នាំ ចាប់ផ្តើម | ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| **វាលអណ្តូងស្នាន់ខាងកើតបឹងត្រសែង** | ៦.៣៨ | ♣ រាំង | • ផ្សព្វផ្សាយពីផលប្រយោជន៍ ព្រៃលិចទឹក | ០៥/២០១៩ | ០៣/២០២០ |
| | | ♣ ផ្តោល | • ដាំកូនឈើ និងដាក់ស្លាកសញ្ញា | ០៦/២០១៩ | ១១/២០១៩ |
| | | ♣ ត្លួរ | • ថែរក្សា និងការពារ | ០៦/២០១៩ | ០៣/២០២០ |
| | | ♣ ប្រកែង | • ត្រួតពិនិត្យ និងការពារ | ជាប្រចាំ | |

## គ.៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ការនេសាទត្រី ការចិញ្ចឹមត្រី ជាមុខរបរចំបងរបស់ប្រជានេសាទនៅក្នុងសហគមន៍**បឹងត្រសែង** ជាទូទៅ ប្រជាពលរដ្ឋ ក្នុងសហគមន៍នេសាទនេះ ច្រើនចិញ្ចឹមត្រី ដែលការចិញ្ចឹមត្រីមានដូចជា ត្រីកង្ហែប និងត្រីអណ្តែង។

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់នៅក្នុងវិស័យជលផលក្នុងការបង្កើនត្រីសាច់ សម្រាប់បរិភោគរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានសម្រាប់នាំចេញទៅទីផ្សារ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។

***ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ៣២៥ ប្រ.កសក ស្តីពីការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្តោរ ដែលត្រូវបានអនុវត្តការប្រជាពលរដ្ឋនៅមូលដ្ឋាន។***

ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទ**បឹងត្រសែង** ក្នុងគោលបំណង ៖

- បង្កើនត្រីសាច់សម្រាប់បរិភោគ របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលទទួលបានពីការត្រី
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

**ផែនការរៀបចំអភិវឌ្ឍន៍វារីវប្បកម្មក្នុងកន្លែងនេសាទសហគមន៍ បឹងត្រសែង ដូចខាងក្រោម៖**

| ប្រភេទ វារីវប្បកម្ម | សកម្មភាព | ចំនួន គ្រួសារ | ប្រភេទកូន ត្រីពូជ | បរិមាណកូន ត្រីពូជ | ខែ/ឆ្នាំ ចាប់ផ្តើម | ខែ/ឆ្នាំ ប្រមូលផល |
|---|---|---|---|---|---|---|
| ចិញ្ចឹមត្រីក្នុងស្រះ | - បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- ធ្វើបែឬស្សីចិញ្ចឹម<br>- ផ្តល់កូនត្រី<br>- តាមដានត្រួតពិនិត្យ | ២០ | អណ្តែងកូនកាត់ | ១០០០០ក្បាល | ១០/៩/១៩ | ៣០/៩/២០ |
| ចិញ្ចឹមកង្ហែបក្នុងស្រះ | | ១០០ | កង្ហែប | ៥០០០ក្បាល | ១០/៩/១៩ | ៣០/៩/២០ |

## គ.៦. ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

កម្មការសហគមន៍ **បឹងត្រសែង** បានដើរតួនាទីសំខាន់ ក្នុងការស្វែងរកប្រាក់ចំណូល និងចំណាយផ្សេងៗ ដូចជាភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ការគាំទ្រពីឃុំ ចំណូលពីក្រុមសន្សំប្រាក់។

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ឆ្នាំចាប់ផ្តើម | ឆ្នាំបញ្ចប់ | ចំណូលសរុបរៀល |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ប្រមូលថវិកាពីសមាជិកភាព | ១០/២០១៩ | ១០/២០២០ | ១៥៦.០០០ រៀល |
| ភាគទានប្រចាំឆ្នាំ | ប្រមូលភាគទាន១ដង/១ឆ្នាំ | ១២/២០១៩ | ១២/២០១៩ | ៤៦៨.០០០ រៀល |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ភាគទានអ្នកនេសាទខាងក្រៅ | ២០១៩ | ២០២០ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិក | ២០១៩ | ២០២០ | |
| ភាគទានពីក្រុមសន្សំ | ប្រមូលប្រាក់បដិភាគពីក្រុមសន្សំ | ២០១៩ | ២០២០ | |

## គ.៧. ផែនការចុះល្បាតរបស់សហគមន៍នេសាទ

គោលបំណង

- ថែរក្សាការពារកន្លែងអភិរក្សត្រីមេពូជ
- ទប់ស្កាត់បទល្មើសនេសាទក្នុងកន្លែងនេសាទសហគមន៍។

| កម្មវិធីល្បាត | សម្ភារៈល្បាត | អ្នកចូលរួម | សកម្មភាព | ចាប់ផ្តើម | បញ្ចប់ |
|---|---|---|---|---|---|
| ល្បាត១ខែ ៧ដង | ទូក កាណូត ពិល មុង អង្រឹង អាវភ្លៀង...... | - ក្រុមល្បាត<br>- គណៈកម្មការ | - ត្រួតពិនិត្យតំបន់អភិរក្ស<br>- កន្លែងនេសាទសហគមន៍ | ២០១៩ | ២០២១ |

## គ.៨. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅបេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទ**បឹងត្រសែង** ត្រូវមានចំណេះដឹង ដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើស ជាគណៈកម្មការ បានប្រើនីតិវិធី ដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែងគណៈកម្មការសហគមន៍នេសាទ**បឹងត្រសែង** ត្រូវបានជ្រើសរើស តាមរយៈការបោះឆ្នោតដោយ ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាព គណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនង ជាមួយដៃគូអភិវឌ្ឍន៍ និងការរៀប ផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។

| ផែនការ | ប្រធានបទ/ជំនាញ | អ្នកទទួលខុសត្រូវ | ពេលវេលា | ថវិកា |
|---|---|---|---|---|
| ការពង្រឹងសមត្ថភាព | កំណត់ហេតុនិងរបាយការណ៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | សេរលិខិតរដ្ឋបាល | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | រៀបចំទុកដាក់ឯកសារ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| ការងារគ្រប់គ្រង | របៀបកត់ត្រាប្រចាំថ្ងៃ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | ការគ្រប់គ្រងថវិកា | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | ការដោះស្រាយទំនាស់ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | ១,៤០០,០០០៛ |
| | សរសេរ សំណើសុំថវិកា | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ២ដង | |
| | រៀបចំបណ្តាញសហគមន៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | ១,៤០០,០០០៛ |
| | សិក្សាផ្លាស់ប្តូរបទពិសោធន៍ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | |
| បច្ចេកទេស | ដាំបន្លែ | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | [illegible] |
| បច្ចេកទេស | ចិញ្ចឹមត្រី មាន់ ទា ជ្រូក | សមាជិកនិងគណៈកម្មការ | មួយឆ្នាំ១ដង | ៧០០,០០០៛ |

## គ.៩. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្នធនធានជលផលក្នុងសហគមន៍នេសាទ**មឹងត្រសែង** កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃលិចទឹក និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានា ការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះតម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និង លិខិតបទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួម ចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។

